**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃជំរឿនកសិកម្ម នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីកាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ ក្នុងការទទួលបាននូវព័ត៌មានគ្រប់ផ្នែកក្នុងវិស័យកសិកម្មនិងធ្វើជាទិន្នន័យមូលដ្ឋានសម្រាប់អ្នកប្រើប្រាស់និងអ្នករៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងនានា សំដៅពង្រឹងនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស្ថិតិកសិកម្ម ដើម្បីជំរុញកិច្ចអភិវឌ្ឍវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ច។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើគ្រប់ការកាន់កាប់ផលិតកម្មកសិកម្មនិងអ្នកកាន់កាប់ផលិតកម្មកសិកម្មទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

១- **ការកាន់កាប់ផលិតកម្មកសិកម្ម** សំដៅដល់អង្គភាពសេដ្ឋកិច្ចនៃផលិតកម្មកសិកម្ម ក្រោមការគ្រប់គ្រងតែមួយ រួមមានរាល់ដំណាំគ្រប់ប្រភេទ បសុសត្វចិញ្ចឹមគ្រប់ប្រភេទ ត្រីចិញ្ចឹមគ្រប់ប្រភេទវារីវប្បកម្ម និងរាល់ដីធ្លីបានប្រើប្រាស់ទាំងមូលឬមួយផ្នែកសម្រាប់គោលបំណងផលិតកម្មកសិកម្មដោយមិនគិតពីកម្មសិទ្ធិឬទម្រង់ផ្លូវច្បាប់។ ការកាន់កាប់ផលិតកម្មកសិកម្ម អាចមានក្បាលដីមួយឬច្រើន ដែលស្ថិតនៅក្នុងតំបន់មួយឬច្រើនដោយឡែកពីគ្នា ក្នុងរាជធានី ខេត្តតែមួយ ឬក្នុងតំបន់ត្រួតត្រាមួយឬច្រើន ឬតំបន់រដ្ឋបាលនៃប្រទេស ដែលមាន ក្បាលដីប្រើមធ្យោបាយផលិតកម្មតែមួយ ដូចជាពលកម្ម អគារកសិដ្ឋាន គ្រឿងយន្ត ឬសត្វអូសទាញ។

២- **ជំរឿនកសិកម្ម** សំដៅដល់ការប្រមូលទិន្នន័យអំពីការប្រើប្រាស់ដីធ្លី ការដាំដុះដំណាំគ្រប់ប្រភេទ ការចិញ្ចឹមសត្វគ្រប់ប្រភេទ ជលផល និងវារីវប្បកម្មក្នុងរយៈពេលយោងជាក់លាក់។

៣- **អ្នកកាន់កាប់ផលិតកម្មកសិកម្ម** សំដៅដល់គ្រួសារ ឬនីតិបុគ្គលដែលគ្រប់គ្រងនិងធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ លើការប្រតិបត្តិនៃការកាន់កាប់ផលិតកម្មកសិកម្ម។

## ជំពូកទី២
## កាលបរិច្ឆេទ

**មាត្រា៤ .-**

ត្រូវបានកំណត់យកថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ ជាកាលបរិច្ឆេទនៃជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣។ ៧៤ ០៧

## ជំពូកទី៣
## យន្តការនិងនីតិវិធី

**មាត្រា៥ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិជំរឿនកសិកម្មឆ្នាំ២០២៣ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងផែនការ | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងផែនការ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម | សមាជិក |
| - អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ | លេខាធិការ ។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការជាតិជំរឿនកសិកម្មឆ្នាំ២០២៣ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៦ .-**

គណៈកម្មាធិការជាតិជំរឿនកសិកម្មឆ្នាំ២០២៣ ត្រូវបង្កើតគណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម គណៈកម្មការឃោសនាជំរឿនកសិកម្ម និងគណៈកម្មការជំរឿនកសិកម្មរាជធានី ខេត្ត ដែលកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិជំរឿនកសិកម្មឆ្នាំ២០២៣។

**មាត្រា៧ .-**

គណៈកម្មាធិការជាតិជំរឿនកសិកម្មឆ្នាំ២០២៣ មានភារកិច្ច៖

- ណែនាំនិងអនុម័តរាល់កិច្ចការទូទៅដែលពាក់ព័ន្ធនឹងជំរឿនកសិកម្ម

- រៀបចំនិងបង្កើតគណៈកម្មការបច្ចេកទេសជំរឿនកសិកម្មនិងគណៈកម្មការឃោសនាជំរឿនកសិកម្ម សម្រាប់អនុវត្តផ្ទាល់រាល់ការងារបច្ចេកទេសក្នុងការជំរឿនកសិកម្ម
- រៀបចំនិងបង្កើតគណៈកម្មការជំរឿនកសិកម្មរាជធានី ខេត្ត
- ចាត់តាំងមន្ត្រីឱ្យចូលរួមជំរឿនកសិកម្ម តាមការស្នើសុំរបស់គណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពីការប្រព្រឹត្តទៅនិងលទ្ធផលនៃជំរឿនកសិកម្ម
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ឱ្យពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៨ .-**

គណៈកម្មាធិការជាតិជំរឿនកសិកម្មឆ្នាំ២០២៣ ត្រូវរៀបចំកិច្ចប្រជុំយ៉ាងតិច៦(ប្រាំមួយ)ខែម្តង តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំជាវិសាមញ្ញបាន។

ក្នុងករណីប្រធានគណៈកម្មាធិការជាតិជំរឿនកសិកម្មឆ្នាំ២០២៣ អវត្តមាន អនុប្រធានណាមួយដែលបានទទួលសិទ្ធិពីប្រធានត្រូវដឹកនាំកិច្ចប្រជុំ។

**មាត្រា៩ .-**

គណៈកម្មាធិការជាតិជំរឿនកសិកម្មឆ្នាំ២០២៣ គណៈកម្មការបច្ចេកទេសជំរឿនកសិកម្មនិងគណៈកម្មការឃោសនាជំរឿនកសិកម្ម មានទីតាំងនៅក្រសួងផែនការនិងមានសិទ្ធិប្រើត្រារបស់ក្រសួងផែនការ។

គណៈកម្មការជំរឿនកសិកម្មរាជធានី ខេត្ត មានសិទ្ធិប្រើត្រារបស់រដ្ឋបាលរាជធានី ខេត្ត។

**មាត្រា១០ .-**

ប្រធានគណៈកម្មាធិការជាតិជំរឿនកសិកម្មឆ្នាំ២០២៣មានសិទ្ធិស្នើសុំមន្ត្រីពីបណ្តាក្រសួង ស្ថាប័ន និងប្រជាជនដើម្បីសហការជួយធ្វើកិច្ចការជំរឿនកសិកម្ម។

**មាត្រា១១ .-**

ជំរឿនកសិកម្ម ឆ្នាំ២០២៣ ត្រូវមានដំណាក់កាលដូចតទៅ៖

១- កិច្ចប្រតិបត្តិការនៅឆ្នាំ២០២២ មុនជំរឿន រួមមាន៖
  - ការស្រង់បញ្ជីគ្រួសារកសិកម្មនិងសហគ្រាសកសិកម្ម
  - ការរៀបចំនិងគូរផែនទីមណ្ឌលជំរឿន
  - ការធ្វើអង្កេតនិងជំរឿនសាកល្បងលើគ្រួសារកសិកម្ម និងសហគ្រាសកសិកម្មសំណាកគំរូ។

២- កិច្ចប្រតិបត្តិការក្នុងពេលជំរឿនកសិកម្មឆ្នាំ២០២៣៖ ការធ្វើសម្ភាសន៍លើការកាន់កាប់ផលិតកម្មកសិកម្មនិងអ្នកកាន់កាប់ផលិតកម្មកសិកម្ម។

៣- កិច្ចប្រតិបត្តិការក្រោយជំរឿន រួមមាន៖
  - ការធ្វើអង្កេតសម្រាប់វាយតម្លៃលើការងារជំរឿនដែលបានធ្វើហើយ
  - ការធ្វើអង្កេតផ្សេងទៀតក្នុងករណីចាំបាច់
  - ការរៀបចំ ចងក្រង និងវិភាគរបាយការណ៍ជំរឿនកសិកម្ម
  - ការផ្សព្វផ្សាយលទ្ធផលជំរឿនកសិកម្មថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**មាត្រា១២ .-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការជាអគ្គនាយកជំរឿនកសិកម្ម និងត្រូវមានមន្ត្រីរដ្ឋបាល និងមន្ត្រីបច្ចេកទេសនៃវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងមន្ត្រីបច្ចេកទេស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរផែនការ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ជួយរាល់ការងារជំរឿន។

**មាត្រា១៣ .-**

មន្ត្រីជំរឿន ដែលរួមមានអ្នកត្រួតពិនិត្យការសម្ភាស អ្នកសម្ភាសស្រង់ទិន្នន័យព័ត៌មាន និង ភ្នាក់ងារជំនួយការដល់កិច្ចសហប្រតិបត្តិការជំរឿន ត្រូវចាត់តាំងដោយប្រធានគណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០២៣ តាមការស្នើសុំរបស់អគ្គនាយកជំរឿនកសិកម្ម។ ការចាត់ចែងនេះអនុវត្តបានតែក្នុងកំលុងពេលជំរឿនតែប៉ុណ្ណោះ។

**មាត្រា១៤ .-**

អ្នកកាន់កាប់ផលិតកម្មកសិកម្ម ត្រូវសហការនិងអនុញ្ញាតឱ្យមន្ត្រីបំពេញការងារជំរឿនដែលបង្ហាញលិខិតបេសកកម្មផ្លូវការ បានចូលក្នុងទីតាំងនៃផលិតកម្មកសិកម្ម លំនៅឋាន ឬទីកន្លែងរបស់ខ្លួនក្នុងគោលដៅនៃការធ្វើជំរឿន និងអនុញ្ញាតឱ្យមន្ត្រីទាំងនោះអាចលាបពណ៌ បិទអក្សរ បិទសញ្ញាឬលេខសម្គាល់ នៅតាមកន្លែងចាំបាច់ សម្រាប់បម្រើដល់ការងារជំរឿនកសិកម្ម។

**មាត្រា១៥ .-**

ប្រធានគណៈកម្មាធិការជាតិជំរឿនកសិកម្មឆ្នាំ២០២៣ អាចចាត់តាំងអ្នកគ្រប់គ្រងជំរឿនកសិកម្មតាមទីកន្លែងដែលមានលក្ខណៈពិសេសដូចខាងក្រោម៖

ក- ទីតាំងផលិតកម្មកសិកម្មសាធារណៈនិងឯកជនដែលមានទ្រង់ទ្រាយធំ។

ខ- ទីតាំងផលិតកម្មកសិកម្មផ្សេងទៀតដែលចាំបាច់។

**មាត្រា១៦ .-**

មន្ត្រីដែលគ្មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការធ្វើជំរឿន គ្មានសិទ្ធិត្រួតពិនិត្យរាល់សៀវភៅ បញ្ជី ឬសំណៅកត់ត្រាដែលបានធ្វើឡើងដោយមន្ត្រីជំរឿនបានឡើយ។

## ជំពូកទី៤
## ប្រភពធនធាន

**មាត្រា១៧ .-**

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ មានប្រភពធនធានដូចតទៅ៖

- ថវិកាជាតិ
- ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍនានា
- ប្រភពធនធានស្របច្បាប់ផ្សេងៗទៀត។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

កិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ